01109928

F26/1/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jun-2015, 14:18
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

# សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលសម្រាប់ដាក់សេចក្តីជំទាស់

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (“**អង្គជំនុំជម្រះតុលាការកំពូល**” និង“**អ.វ.ត.ក**”),

**កត់សម្គាល់**ដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ[1]របស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ២, ៣, ៦ និង ក្នុងករណីចាំបាច់ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៥ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5 (“ដីកាកំណត់កាលបរិច្ឆេទសវនាការ”),

**កត់សម្គាល់** សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ ដែល*ក្នុងចំណោមនោះ* បានតម្រូវឱ្យភាគីដាក់បញ្ជីឯកសារដែលខ្លួនមានបំណងចង់ប្រើប្រាស់ក្នុងអំឡុងពេលសួរសំណួរសាក្សី ត្រឹមថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ និងដាក់សេចក្តីជំទាស់ណាមួយទៅលើឯកសារទាំងនោះត្រឹមថ្ងៃ សុក្រទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥[2],

**កត់សម្គាល់**លើសំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំពន្យារពេលកំណត់សម្រាប់ការដាក់សេចក្តីជំទាស់ទៅនឹងការប្រើប្រាស់ឯកសារ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី[3] ដែលសំណើនេះ សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលពន្យារកាលបរិច្ឆេទដែលបានលើកឡើងខាងលើ សម្រាប់ដាក់សេចក្តីជំទាស់ នៅថ្ងៃ ច័ន្ទ ទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ដោយមូលហេតុថា សេចក្តីជំទាស់ នឹងត្រូវដាក់ជាភាសាខ្មែរ រួមជាមួយភាសាអង់គ្លេស ឬភាសាបារាំង ហើយមេធាវីការពារក្តី ខៀវ សំផន មានតែមួយថ្ងៃប៉ុណ្ណោះ គឺថ្ងៃ ព្រហស្បតិ៍ ទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ ដើម្បីធ្វើការលើបញ្ហានេះ ប៉ុន្តែ នៅថ្ងៃដដែលនោះ មេធាវីការពារក្តី នឹងជាប់រវល់នៅក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ មេធាវី ស្នើសុំយ៉ាងតិចត្រឹមថ្ងៃសុក្រ និងនៅចុងសប្តាហ៍ ដើម្បីពិនិត្យលើឯកសារ ដែលភាគីដទៃទៀតមានបំណងប្រើប្រាស់ និងធ្វើសេចក្តីជំទាស់ណាមួយលើប្រឆាំងនឹងការប្រើប្រាស់ឯកសារនោះ[4],

[1] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F24 (សំណៅដែលត្រូវបានកែប្រែដាក់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥) (“ដីកាកំណត់កាលបរិច្ឆេទសវនាការ”)។

[2] ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ F26 ទំព័រ ៤ ដល់ ៥ (កថាខណ្ឌទីបីដែលត្រូវអនុវត្ត)។

[3] ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ F26/1 (“សំណើសុំពន្យារពេល”)។

[4] សំណើសុំពន្យារពេល កថាខណ្ឌ ៥ ដល់ ៧។

**កត់សម្គាល់** វិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង ដែលចែងថា អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចពន្យារកាលបរិច្ឆេទដែលខ្លួនបានកំណត់ ទៅតាមសំណើសុំរបស់ភាគី ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន,

**ពិចារណាឃើញ** ថា ខៀវ សំផន បានបង្ហាញនូវមូលហេតុត្រឹមត្រូវក្នុងការសុំពន្យារកាលបរិច្ឆេទដែលបានលើកឡើងខាងលើ សម្រាប់ដាក់សេចក្តីជំទាស់ ហើយការស្នើសុំពន្យាពេលនេះ មានលក្ខណៈសមហេតុផល,

**អាស្រ័យហេតុនេះ**

**សម្រេច** ពន្យារកាលបរិច្ឆេទដែលបានកំណត់នៅក្នុងសេចក្តីណែនាំស្តីពីកិច្ចនីតិវិធីសវនាការសម្រាប់ដាក់សេចក្តីជំទាស់ទៅនឹងឯកសារដែលមានបំណងប្រើប្រាស់ក្នុងអំឡុងពេលតាំងសំណួរត្រឹមថ្ងៃ ច័ន្ទ ទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥។

.

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**